# តើសាសនាទាំងអស់ដូចគ្នាមែនដែរឬទេ?

**និពន្ធ និងរៀបរៀងដោយ**

សមាគមស្វែងរកប្រាជ្ញាព្រះគម្ពីរព្រះយេស៊ូវ

ស្វែងរកប្រាជ្ញា ស្គាល់ព្រះជាម្ចាស់ គោរពសេចក្ដីពិត

www.facebook.com/SeekingtheWisdomofJesusinKhmer

© រក្សាសិទ្ធិ ២០២៤

# សេចក្តីដើម

មនុស្សជាច្រើនគិតថា សាសនាទាំងអស់ដូចគ្នា ពីព្រោះសាសនាទាំងអស់តែងតែបង្រៀនមនុស្សឲ្យធ្វើល្អ កុំធ្វើអាក្រក់។ តើគំនិតនេះត្រឹមត្រូវដែរឬទេ? តើការបង្រៀនរបស់សាសនាទាំងអស់ មានមូលដ្ឋានដូចគ្នាដែរឬទេ? តាមពិតទៅ សាសនាភាគច្រើនមានលក្ខណៈស្រដៀងគ្នាដូចខាងក្រោមនេះ ៖

# សាសនាទាំងអស់បង្រៀនមនុស្សឲ្យធ្វើល្អ កុំធ្វើអាក្រក់

មនុស្សទូទៅទទួលស្គាល់ថា ការប្រព្រឹត្តអាក្រក់នឹងនាំមកនូវផលអាក្រក់ ដូចជាទុក្ខវេទនា ជំងឺ ភាពក្រីក្រ ភាពអាម៉ាស់ ជាដើម។ ផលអាក្រក់ទាំងនេះអាចប៉ះពាល់ដល់អ្នកដទៃបាន ដូចជា គ្រួសារ និងសង្គម។ ហេតុនេះហើយបានជា សាសនាផ្សេងៗបង្រៀនច្បាប់ទ្រឹស្តី សីលធម៌ និងគោលការណ៍ ដើម្បីជួយការពារសង្គម គ្រួសារ និងជួយមនុស្សគ្រប់ៗគ្នាកុំឲ្យប្រព្រឹត្តអំពើបាប។ ប៉ុន្តែទោះបីជាមនុស្សខំប្រឹងធ្វើល្អក៏ដោយ ក៏យើងមិនអាចបញ្ឈប់ខ្លួនឯងពីការប្រព្រឹត្តអំពើបាបបានឡើយ។ ដូច្នេះ បើយើងប្រព្រឹត្តអំពើបាប ធ្វើដូចម្តេចឲ្យយើងដោះស្រាយបញ្ហាបាបបាន? តើសាសនាបង្រៀនមនុស្សឲ្យចេះដោះស្រាយបញ្ហាបាបដែរឬទេ?



សាសនាទាំងអស់បង្រៀនមនុស្សឲ្យធ្វើល្អ កុំធ្វើអាក្រក់ ដើម្បីការពារខ្លួន និងគ្រួសារ ពីផលអាក្រក់នៃអំពើបាប។

# សាសនាភាគច្រើនបង្រៀនមនុស្សឲ្យដោះស្រាយបញ្ហាបាប

យើងទាំងអស់គ្នាដឹងថា មនុស្សទាំងអស់ធ្វើបាប ហើយគេត្រូវទទួលផលមិនល្អនោះតបមកវិញ។ ហេតុនេះហើយបានជា សាសនាភាគច្រើនបង្រៀនយើងឲ្យដោះស្រាយបញ្ហាបាបរបស់ខ្លួនដោយត្រូវធ្វើអំពើល្អឲ្យបានច្រើនជាងអំពើអាក្រក់។ ឧទាហរណ៍៖ មានសាសនាមួយបានបង្រៀនថា នៅពេលព្រះរបស់គេជំនុំជម្រះមនុស្ស ទ្រង់នឹងថ្លឹងថ្លែងគ្រប់ទាំងការប្រព្រឹត្តរបស់គេ ប្រសិនបើទ្រង់ទតឃើញថា ការប្រព្រឹត្តល្អរបស់គេច្រើនជាងការអាក្រក់ នោះទើបទ្រង់អនុញ្ញាតឲ្យគេចូលស្ថានបរមសុខបាន ។

មានសាសនាមួយផ្សេងទៀតបានបង្រៀនថា បើធ្វើអាក្រក់ក្នុងជីវិតនេះ នៅជាតិក្រោយនឹងត្រូវរងទុក្ខវេទនាជាខ្លាំង។ ផ្ទុយទៅវិញ បើធ្វើអំពើល្អ ដូចជាថ្វាយតង្វាយដ៏ធំដល់ព្រះផ្សេងៗ នៅជាតិក្រោយអ្នកនោះនឹងមានជីវិតសប្បាយរីករាយ។ សាសនាទាំងពីរនេះមានព្រះផ្សេងពីគ្នា ហើយមានរបៀបប្រព្រឹត្ត របៀបថ្វាយបង្គំ និងជំនឿអំពីជាតិក្រោយក៏ខុសគ្នាដែរ។ ក៏ប៉ុន្តែ ក្នុងសាសនាទាំងពីរនេះ មានទ្រឹស្តីស្រដៀងគ្នាមួយគឺថា មនុស្សដែលបានប្រព្រឹត្តអំពើបាបត្រូវតែខំប្រឹងដោះស្រាយបញ្ហាបាបរបស់ខ្លួនដោយប្រព្រឹត្តល្អឲ្យច្រើនជាងការអាក្រក់។ ដូច្នេះ ទាក់ទងនឹងរបៀបដោះស្រាយនៃអំពើបាប សាសនាភាគច្រើនគេបង្រៀនដូចគ្នា បើដូច្នេះមែន តើយើងត្រូវធ្វើបុណ្យប៉ុន្មាន ដើម្បីឲ្យខ្លួនបានរួចពីបាប?



សាសនាភាគច្រើនបង្រៀនយើងឲ្យដោះស្រាយបញ្ហាបាបរបស់ខ្លួនដោយត្រូវធ្វើអំពើល្អឲ្យបានច្រើនជាងអំពើអាក្រក់។

# តើមនុស្សយើងត្រូវធ្វើអំពើល្អប៉ុន្មានដើម្បីឲ្យរួចពីបាប?

មនុស្សច្រើនខំប្រឹងប្រតិបត្តិតាមការបង្រៀននៃសាសនារបស់ខ្លួន ហើយយកចិត្តទុកដាក់ធ្វើអំពើល្អច្រើនជាងអំពើអាក្រក់ដើម្បីដោះស្រាយបញ្ហាបាបខ្លួនឯង។ តើគេត្រូវធ្វើអំពើល្អឲ្យបានច្រើនប៉ុណ្ណា ទើបអាចជួយឃឹតយោងខ្លួនបាន? តើគេធ្វើយ៉ាងណា ទើបដឹងថា គេបានប្រព្រឹត្តអំពើល្អឲ្យបានគ្រប់គ្រាន់ហើយ? មានសុភាសិតខ្មែរមួយបានចែងថា «ធ្វើបុណ្យមួយរយសំពៅ បាបមួយចូលទៅរលាយបាត់អស់»។ យោងទៅលើសុភាសិតនេះមានន័យថា អំពើអាក្រក់មានទម្ងន់ធ្ងន់ជាងអំពើល្អ ដោយសារអំពើបាបតែមួយស៊ីបំផ្លាញអំពើល្អទាំងអស់បាន។ នេះពិតជាត្រឹមត្រូវមែន! ហើយព្រះគម្ពីរព្រះយេស៊ូវបានចែងថា «អស់ទាំងអំពើសុចរិតរបស់យើងខ្ញុំក៏ដូចជាអាវកខ្វក់ហើយ»[1]។ ខនេះមានន័យថា ទោះបីជាយើងខំប្រឹងយកចិត្តទុកដាក់លើការប្រព្រឹត្តអំពើល្អអស់ពីដួងចិត្តយ៉ាងណាក៏ដោយ ក៏នៅចំពោះព្រះជាម្ចាស់ គ្រប់ទាំងអំពើល្អរបស់យើងនៅតែជាការអាក្រក់គួរឲ្យស្អប់ខ្ពើមដដែល ហើយខ្វះមិនដល់ខ្នាតនៃព្រះ ដោយសារព្រះមានព្រះបន្ទូលថា «អ្នករាល់គ្នាត្រូវបរិសុទ្ធ ដ្បិតយើងបរិសុទ្ធ»[2]។

---

[1] ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ អេសាយ ៦៤:៦

[2] ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ ១ ពេត្រុស ១:១៦



មានសុភាសិតខ្មែរមួយបានចែងថា «ធ្វើបុណ្យមួយរយសំពៅ បាបមួយចូលទៅរលាយបាត់អស់»

# ហេតុអ្វីបានជាបាបធ្ងន់ជាងអំពើល្អដូច្នេះ?

ដើម្បីដឹងថា ហេតុអ្វីបាបធ្ងន់ដូច្នេះ យើងត្រូវមើលពីប្រវត្តិរបស់បាប និងមនុស្ស ហើយនឹងរបៀបដែលបាបដំបូងបានចូលមកពិភពលោកនេះ។ ព្រះគម្ពីរព្រះយេស៊ូវបានកត់ទុកប្រវត្តិរបស់មនុស្សលោកតាំងពីដំបូងមក ដែលបានចែងថា មុនដំបូងបង្អស់ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើឲ្យល្អឥតខ្ចោះ។ ទ្រង់បានបង្កើតមនុស្សដំបូងពីរនាក់ គឺប្រុសម្នាក់ និងស្រីម្នាក់។ ពួកគាត់មានលក្ខណៈល្អឥតសៅហ្មង ហើយក៏មិនចេះប្រព្រឹត្តអំពើបាបផងដែរ។ ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យចំនឹងរូបអង្គទ្រង់ ហើយបានតាំងបុព្វបុរសដំបូងទាំងពីរនាក់នោះឲ្យមានអំណាចលើរបស់សព្វសារពើ ហើយបានតាំងពួកគាត់ជាតំណាងរបស់ទ្រង់ទៀតផង។ គាត់ទាំងពីរនាក់មានទំនាក់ទំនងល្អឥតខ្ចោះជាមួយព្រះជាម្ចាស់ ហើយពួកគាត់មានសុខភាពល្អ មិនខ្វះខាត មិនមានភាពអាម៉ាស់ ទុក្ខលំបាក និងសេចក្តីស្លាប់ឡើយ។ ពួកគាត់មានជីវិតរស់នៅយ៉ាងល្អប្រសើរដោយព្រះគុណរបស់ព្រះជាម្ចាស់។

ប៉ុន្តែក្រោយមក ពួកគាត់បានបះបោរទាស់នឹងព្រះជាម្ចាស់។ ពួកគាត់លែងគោរពទ្រង់ និងរមិលគុណដាក់ព្រះដែលបានបង្កើតខ្លួនមក។ នេះហើយគឺជាដើមដំបូងនៃអំពើបាប ហើយវាបានឆ្លងមកពីមួយជំនាន់ទៅមួយជំនាន់ ពីឪពុកម្តាយដល់កូន រហូតដល់បច្ចុប្បន្ននេះ។ តាំងពីការបះបោររបស់ពួកគាត់មក មនុស្សជាតិទាំងឡាយ រួមទាំងអ្នកនិងខ្ញុំ ក៏បានទាស់នឹងព្រះជាម្ចាស់ដូចជាបុព្វបុរសពីដំបូងដែរ។ លើសពីនេះទៀត ពួកយើងបានបន្ថែមទោសនៃអំពើបាបជារៀងរាល់ថ្ងៃដោយប្រមាថព្រះអង្គ និងរមិលគុណដាក់ព្រះ ដែលបានបង្កើតខ្លួនមក។



ព្រះជាម្ចាស់បានបង្កើតមនុស្សឲ្យចំនឹងរូប
អង្គទ្រង់ ហើយបានតាំងបុព្វបុរសដំបូងនោះ
ឲ្យមានអំណាចលើរបស់សព្វសារពើដែល
ទ្រង់បានបង្កើតមក។

## តើពួកយើងបានប្រព្រឹត្តអំពើបាបអ្វីខ្លះទាស់នឹងព្រះ ហើយរមិលគុណចំពោះទ្រង់យ៉ាងដូចម្ដេច?

មនុស្សខ្លះឆ្ងល់ថា «ខ្ញុំមិនស្គាល់ព្រះជាម្ចាស់ផ្ទាល់ទេ! តើខ្ញុំប្រព្រឹត្តអំពើបាបទាស់នឹងទ្រង់យ៉ាងម៉េចកើត?» ពេលណាពួកយើងប្រព្រឹត្តអំពើបាបទាស់នឹងគ្នាទៅវិញទៅមក យើងក៏ធ្វើបាបទាស់នឹងព្រះជាម្ចាស់ផងដែរ ពីព្រោះព្រះបានបង្កើតមនុស្សលោកដូចជារូបអង្គទ្រង់។ ហេតុនេះហើយបានជា ព្រះជាម្ចាស់បង្គាប់យើងថា «ត្រូវស្រឡាញ់បងប្អូនឯទៀតៗឲ្យដូចស្រឡាញ់ខ្លួនឯង»[3]។ ដូច្នេះ ពេលណាពួកយើងកុហកគេ និយាយដើមគេ ជេរប្រមាថគេ បោកបញ្ឆោតគេ លួចគេ ខឹងគេ លោភលន់ចង់បានរបស់គេ ឬសម្លឹងមើលគេដោយចិត្តស្រើបស្រាលនិងតណ្ហា ។ល។ ការប្រព្រឹត្តទាំងនេះគឺជាអំពើបាប ដែលប៉ះពាល់ដល់គេមែន ហើយវាក៏ទាស់នឹងព្រះជាម្ចាស់ដែរ ពីព្រោះទ្រង់បានបង្កើតមនុស្សមក។

[3] ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ ម៉ាថាយ ២២:៣៩



ពេលណាយើងប្រព្រឹត្តអំពើបាបទាស់នឹងគ្នាទៅវិញទៅមក យើងក៏ធ្វើបាបទាស់នឹងព្រះជាម្ចាស់ផងដែរ ពីព្រោះព្រះបានបង្កើតមនុស្សលោកដូចជារូបអង្គទ្រង់។

មនុស្សខ្លះទៀតនិយាយថា «តើខ្ញុំរមិលគុណដាក់ព្រះយ៉ាងម៉េច ដោយសារខ្ញុំមិនស្គាល់ទ្រង់ផ្ទាល់ ហើយមិនដែលប្រមាថទ្រង់ផង?» ពេលគេនិយាយអញ្ចឹងគេភ្លេចថា ព្រះជាម្ចាស់បានបង្កើតសព្វសារពើ ហើយទ្រង់បានប្រទានជីវិត ខ្យល់ដង្ហើម ទឹកភ្លៀងសម្រាប់ដាំដំណាំ សត្វគ្រប់ប្រភេទ បន្លែ ហើយនឹងផ្លែឈើជាដើម។ ក៏ប៉ុន្តែ មនុស្សទូទៅ មិនសរសើរតម្កើងព្រះជាម្ចាស់ ឬអរព្រះគុណទ្រង់នោះឡើយ។ មានវគ្គមួយនៅក្នុងព្រះគម្ពីរបានចែងថា «គេមិនបានតម្កើងព្រះអង្គជាព្រះ ឬអរព្រះគុណព្រះអង្គដែរ . . . ព្រោះគេបានប្ដូរសេចក្ដីពិតអំពីព្រះ យកសេចក្ដីភូតភរ ហើយថ្វាយបង្គំ និងគោរពបម្រើរបស់ដែលកើតមក ជាជាងព្រះដែលបង្កើតរបស់ទាំងនោះ»[4]។ ដូច្នេះ ពេលណាពួកយើងមិនអរគុណព្រះអង្គ ឬក៏ថ្វាយបង្គំចំពោះអ្វីដែលមិនមែនជាព្រះជាម្ចាស់ នោះមានន័យថា យើងបានប្រមាថព្រះអង្គ ហើយរមិលគុណដាក់ព្រះ ដែលបានបង្កើតយើងមក។

## អំពើបាបមានទម្ងន់ធ្ងន់ណាស់ដោយសារៈ

១- គ្រប់អំពើបាបទាំងអស់សុទ្ធតែជាការបះបោរទាស់នឹងព្រះជាម្ចាស់ ដែលបានបង្កើតយើងមក។

២- អំពើបាបបានខណ្ឌផ្ដាច់ទំនាក់ទំនងរវាងព្រះជាម្ចាស់នឹងមនុស្ស។

៣- ពេលយើងប្រព្រឹត្តអំពើបាបមានន័យថា យើងរមិលគុណរដាក់ព្រះជាម្ចាស់ ដែលបានបង្កើនយើងមក។

---

[4] ដកស្រងពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ រ៉ូម ១:២១,២៥



ពេលណាពួកយើងមិនអរគុណព្រះអង្គ ឬក៏ថ្វាយបង្គំចំពោះអ្វីដែលមិនមែនជាព្រះជាម្ចាស់ នោះមានន័យថា យើងបានប្រមាថព្រះអង្គ ហើយរមិលគុណដាក់ព្រះ ដែលបានបង្កើតយើងមក។

# តើលទ្ធផលធ្ងន់ធ្ងរជាងគេបំផុតរបស់បាបគឺជាអ្វី?

មនុស្សជាច្រើនបានរាប់ទុក្ខវេទនាដែលកើតចេញពីបាបគឺជាផលដ៏ធ្ងន់ធ្ងរ។ ប៉ុន្តែអំពើបាបមានលទ្ធផលពីរយ៉ាងដែលធ្ងន់ធ្ងរជាងទុក្ខវេទនាទៅទៀត។

១- **សេចក្ដីស្លាប់៖** ព្រះគម្ពីរព្រះយេស៊ូវបានថែងថា «ឈ្នួលរបស់បាប ជាសេចក្ដីស្លាប់»[5] ខគម្ពីរនេះមានន័យថា យើងទាំងអស់គ្នាត្រូវតែស្លាប់ ពីព្រោះយើងបានប្រព្រឹត្តអំពើបាប ហើយយើងបានរមិលគុណដាក់ព្រះ ដែលបានបង្កើតខ្លួនមក។ ហេតុនេះហើយបានជា មនុស្សទាំងអស់ត្រូវស្លាប់ជាមិនខាន។

២- **ការជំនុំជម្រះ៖** ព្រះគម្ពីរបានថែងថា «បានតម្រូវឲ្យមនុស្សលោកទាំងអស់ស្លាប់ម្ដង រួចមកត្រូវទទួលការជំនុំជម្រះ»[6]។ ផ្អែកលើខនេះបានពន្យល់ថា លទ្ធផលនៃបាបដែលធ្ងន់ជាងគេបំផុតគឺការជំនុំជម្រះរបស់ព្រះជាម្ចាស់ ហើយទ្រង់នឹងទំលាក់អស់មនុស្សដែលប្រព្រឹត្តអំពើបាបទៅក្នុងស្ថាននរក។ ហេតុនេះហើយបានជា ព្រះយេស៊ូវមានព្រះបន្ទូលថា «ត្រូវខ្លាចព្រះអង្គដែលទ្រង់អាចនឹងបំផ្លាញទាំងព្រលឹង និងរូបកាយទៅក្នុងនរកបាន។»[7]

---

5 ដកស្រងពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ រូម ៦:២៣

6 ដកស្រងពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ ហេព្រើរ ៩:២៧

7 ដកស្រងពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ ម៉ាថាយ ១០:២៨



ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរព្រះយេស៊ូវចែងថា «ឈ្នួលរបស់បាបជាសេចក្តីស្លាប់» (រ៉ូម ៦:២៣)

# តើយើងអាចគេចឲ្យរួចផុតពីបាប និងការជំនុំជម្រះយ៉ាងដូចម្តេចបាន?

សាសនាស្ទើរតែទាំងអស់បានបង្រៀនថា យើងត្រូវដោះស្រាយបញ្ហាបាបដោយប្រព្រឹត្តអំពើល្អឲ្យបានច្រើនជាងអំពើអាក្រក់។ ក៏ប៉ុន្តែ យើងរាល់គ្នាគ្មានលទ្ធភាពបញ្ឈប់ខ្លួនឯងពីការប្រព្រឹត្តអំពើបាបមិនបានឡើយ។ ប្រហែលមានមនុស្សខ្លះដែលអាចប្រព្រឹត្តអំពើល្អដ៏ច្រើនបាន ក៏ប៉ុន្តែ បើមានបាបតែមួយចូលទៅរលាយបាត់អស់ ហើយគ្មាននរណាម្នាក់ដែលមិនធ្លាប់ប្រព្រឹត្តអំពើបាបសោះនោះឡើយ។ ហេតុនេះហើយបានជា យើងរាល់គ្នាត្រូវតែប្រឈមមុខនឹងការជំនុំជម្រះរបស់ព្រះជាម្ចាស់មិនខាន រួចត្រូវបោះទំលាក់ទៅស្ថាននរក។ យោងទៅលើបញ្ហាខាងលើនេះ សាសនាភាគច្រើនជួយយើងឲ្យរួចផុតពីបាបមិនបានឡើយ។ តែយ៉ាងណាក៏ដោយ យើងមានសេចក្តីសង្ឃឹមមួយ ដែលជាផ្លូវដ៏ពិតប្រាកដនាំយើងឲ្យបានរួចពីបាបបាន។



«ត្រូវខ្លាចព្រះអង្គ ដែលទ្រង់អាចនឹងបំផ្លាញទាំងព្រលឹង និងរូបកាយទៅក្នុងនរកបាន។»
(ម៉ាថាយ ១០:២៨)

## តើមានផ្លូវណាមួយដែលនាំយើងទៅរកសេចក្ដីសង្ឃឹមបាន?

ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកពីព្រោះទ្រង់បានបង្កើតយើងឲ្យចំនឹងរូបអង្គទ្រង់ ហើយយើងក៏ជាស្នាព្រះហស្ដរបស់ព្រះអង្គផ្ទាល់ផងដែរ។ ហេតុនេះហើយបានជា ពេលព្រះជាម្ចាស់បានឃើញស្ថានភាពអស់សង្ឃឹមរបស់យើងដូច្នេះ ទ្រង់ក៏អាណិតអាសូរយើងខ្លាំងណាស់ រហូតដល់ព្រះអង្គបានចាត់ព្រះរាជបុត្រាតែមួយរបស់ព្រះអង្គដើម្បីរៀបចំផ្លូវនៃសេចក្ដីសង្គ្រោះមួយឲ្យយើង។ ព្រះគម្ពីរបានចែងថា «ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»[8]។ ព្រះរាជបុត្រានោះមានព្រះនាមថា «ព្រះយេស៊ូវ»។ ទ្រង់យាងមកកើតជាមនុស្ស ហើយព្រះគម្ពីរចែងថា «ព្រះយេស៊ូវយាងពីកន្លែងមួយទៅកន្លែងមួយ ទាំងប្រព្រឹត្ដអំពើល្អ និងប្រោសអស់អ្នកដែលត្រូវមារសង្កត់សង្កិនឲ្យបានជា»[9]។ ទោះបីជាព្រះយេស៊ូវមិនដែលប្រព្រឹត្ដអំពើបាបសោះក៏ដោយ ក៏មនុស្សអាក្រក់បាននាំគ្នាស្អប់ព្រះអង្គ ហើយចាប់ទ្រង់ឆ្កាងលើឈើឆ្កាង ព្រមទាំងធ្វើគុតទ្រង់ផងដែរ។ ប៉ុន្ដែ ព្រះគម្ពីរចែងទៀតថា «ព្រះជាម្ចាស់បានប្រោសព្រះអង្គឲ្យមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី»[10]។

---

8 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ យ៉ូហាន ៣:១៦

9 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ កិច្ចការ ១០:៣៨

10 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ កិច្ចការ ១០:៤០



ព្រះជាម្ចាស់បានរៀបចំផ្លូវមួយឲ្យយើង ដោយបានចាត់ព្រះរាជបុត្រាតែមួយរបស់ព្រះអង្គឲ្យយាងមកផែនដីនេះ ដើម្បីសង្គ្រោះយើងឲ្យរួចផុតពីបាប និងលទ្ធផលនៃបាប។

ហេតុការណ៍ទាំងអស់នេះកើតឡើងតាមគម្រោងការណ៍របស់ព្រះជាម្ចាស់ ដើម្បីទ្រង់អាចរៀបចំផ្លូវរំដោះមនុស្សយើងឲ្យរួចផុតពីបាប ហើយឲ្យមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ឡើងវិញបាន។ នៅពេលព្រះយេស៊ូវសោយទិវង្គត ទ្រង់បានទទួលសេចក្ដីក្រោធ និងការជំនុំជម្រះពីព្រះជាម្ចាស់មកលើរូបអង្គទ្រង់**ជំនួស**យើង។ ព្រះយេស៊ូវបានថ្វាយព្រះកាយព្រះអង្គផ្ទាល់ធ្វើជាយញ្ញបូជាលាងសំអាតបាបយើង។ យញ្ញបូជារបស់ព្រះយេស៊ូវគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដូច្នេះ ព្រះអង្គបានប្រោសព្រះយេស៊ូវឲ្យមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូវហ្នឹងហើយជាផ្លូវដែលព្រះជាម្ចាស់បានរៀបចំដើម្បីរំដោះយើងឲ្យរួចផុតពីអំពើបាប និងលទ្ធផលនៃបាបរបស់យើង។ ព្រះយេស៊ូវបានផ្ទុកអំពើបាប និងរងការជំនុំជម្រះ**ជំនួស**យើង ប្រយោជន៍ឲ្យយើងបានរាប់ជាសុចរិត មានទំនាក់ទំនងជាមួយព្រះជាម្ចាស់បាន ហើយក៏រំដោះយើងឲ្យរួចពីទោសនៃអំពើបាប និងស្ថាននរកទៀតផង។

សាសនាភាគច្រើនបង្រៀនថា យើងត្រូវខំប្រឹងធ្វើអំពើល្អច្រើនជាងអំពើអាក្រក់ដើម្បីយឹតយោងខ្លួនឲ្យរួចពីបាប ក៏ប៉ុន្តែយើងអត់មានសមត្ថភាពសង្គ្រោះខ្លួនឯងបានឡើយ! ហេតុនេះហើយបានជាព្រះជាម្ចាស់បានរៀបចំផ្លូវមួយដើម្បីសង្គ្រោះយើង។ សាសនាជាទូទៅបង្រៀនថា «ខ្លួនទីពឹងខ្លួន» តែព្រះជាម្ចាស់មានព្រះបន្ទូលថា «មនុស្សទាំងអស់នៅចុងផែនដីអើយ ចូរមើលមកយើង ហើយទទួលសេចក្ដីសង្គ្រោះចុះ»[11] ហើយទ្រង់ក៏មានបន្ទូលទៀតថា «ក្រៅពីយើង គ្មានអ្នកសង្គ្រោះទៀតឡើយ»[12]។

---

11 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ អេសាយ ៤៥:២២

12 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ អេសាយ ៤៣:១១



ព្រះយេស៊ូវបានថ្វាយព្រះកាយព្រះអង្គផ្ទាល់ធ្វើជាយញ្ញបូជាលាងសំអាតបាបយើង។ ព្រះយេស៊ូវនេះហើយជាផ្លូវដែលព្រះជាម្ចាស់បានរៀបចំដើម្បីរំដោះយើងឲ្យរួចផុតពីអំពើបាប និងលទ្ធផលនៃបាបរបស់យើង។

## តើព្រះជាម្ចាស់បានសន្យាអ្វីខ្លះដល់អស់អ្នកដែលសម្រេចចិត្តដើរតាមផ្លូវនៃសេចក្ដីសង្គ្រោះដែលទ្រង់បានរៀបចំឲ្យ?

ព្រះជាម្ចាស់កំពុងត្រាស់ហៅមនុស្សគ្រប់ជាតិសាសន៍ទាំងឡាយឲ្យកែប្រែចិត្ត បែរចេញពីអំពើបាបរបស់ខ្លួន ហើយនិងដើរតាមផ្លូវដែលទ្រង់បានរៀបចំឲ្យ។ ព្រះអង្គមានព្រះបន្ទូលថា «មកចុះ យើងនឹងពិភាក្សាជាមួយគ្នា ទោះបើអំពើបាបរបស់អ្នកដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ»[13] ព្រះអង្គមានព្រះបន្ទូលសន្យាថា ទ្រង់នឹងសំអាតអស់អ្នកដែលសម្រេចចិត្តដើរតាមផ្លូវរបស់ទ្រង់ឲ្យបានស្អាតពីអំពើបាប។ ម្យ៉ាងទៀត ព្រះក៏បានសន្យាផងដែរថា ទ្រង់នឹងប្រទានជីវិតអស់កល្បជានិច្ច**ជំនួស**សេចក្ដីស្លាប់! ដ្បិតព្រះគម្ពីរបានចែងថា «ឈ្នួលរបស់បាប ជាសេចក្ដីស្លាប់ តែអំណោយទានរបស់ព្រះវិញ គឺជីវិតអស់កល្បជានិច្ច នៅក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើង»[14]។ ព្រះអង្គបានសន្យាថា អស់អ្នកណាដែលសម្រេចចិត្តទទួលព្រះយេស៊ូវជាព្រះសង្គ្រោះ អ្នកនោះនឹងមិនស្លាប់ដោយព្រោះអំពើបាបរបស់គាត់ទេ ផ្ទុយទៅវិញ គាត់នឹងទទួលបានជីវិតអស់កល្បជានិច្ច។

---

13 ដកស្រងពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ អេសាយ ១:១៨

14 ដកស្រងពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ រ៉ូម ៦:២៣



ព្រះអង្គមានព្រះបន្ទូលថា «មកចុះ យើងនឹងពិភាក្សាជាមួយគ្នា ទោះបើអំពើបាបរបស់អ្នកដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ» (អេសាយ ១:១៨)

តើជីវិតអស់កល្បជានិច្ចនេះសំដៅទៅលើអ្វី? តើរូបកាយរបស់យើងមិនដែលស្លាប់ឬ? អត់ទេ! ដូចជាព្រះយេស៊ូវមានព្រះជន្មរស់ពីសេចក្តីស្លាប់ឡើងវិញជាយ៉ាងណា នោះអស់អ្នកដែលសម្រេចចិត្តទទួលទ្រង់ជាព្រះអង្គរបស់ខ្លួន នឹងរស់ឡើងវិញជាយ៉ាងនោះដែរ។ ព្រះយេស៊ូវមានព្រះបន្ទូលថា «ខ្ញុំជាសេចក្តីរស់ឡើងវិញ និងជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ»[15] ពេលរូបកាយរបស់យើងស្លាប់ទៅ អស់អ្នកដែលទទួលព្រះយេស៊ូវជាព្រះនៃខ្លួន នោះព្រលឹងវិញ្ញាណពួកគាត់នឹងចូលស្ថានសួគ៌ ហើយរង់ចាំនៅទីនោះរហូតដល់ព្រះយេស៊ូវយាងត្រឡប់មកផែនដីនេះវិញ។ នៅពេលនោះ ទ្រង់នឹងប្រោសរូបកាយពួកគាត់ឲ្យរស់ឡើងវិញអស់កល្បជានិច្ច ហើយពួកគាត់មិនប្រឈមមុខនឹងទុក្ខវេទនាទៀតឡើយ ពីព្រោះព្រះជាម្ចាស់បានសន្យាថា «ព្រះអង្គនឹងជូតអស់ទាំងទឹកភ្នែកចេញពីភ្នែករបស់គេ សេចក្តីស្លាប់នឹងលែងមានទៀតហើយ ការកាន់ទុក្ខ ការយំសោក ឬការឈឺចាប់ ក៏នឹងលែងមានទៀតដែរ»[16]។

15 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ យ៉ូហាន ១១:២៥

16 ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ វិវរណៈ ២១:៤



ព្រះយេស៊ូវមានព្រះបន្ទូលថា «ខ្ញុំជាសេចក្ដីរស់ឡើងវិញ និងជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ» (យ៉ូហាន ១១:២៥)

# សេចក្តីសង្ខេប

សាសនាភាគច្រើនមានការបង្រៀនស្រដៀងគ្នាថា យើងត្រូវដោះស្រាយបញ្ហាបាបដោយប្រព្រឹត្តអំពើល្អឲ្យបានច្រើនជាងអំពើអាក្រក់ ក៏ប៉ុន្តែ យើងរាល់គ្នាគ្មានលទ្ធភាពបញ្ឈប់ខ្លួនឯងពីការប្រព្រឹត្តអំពើបាបមិនបានឡើយ។ យើងអាចធ្វើល្អបាន តែបើយើងចង់ធ្វើល្អឲ្យបានគ្រប់គ្រាន់ដើម្បីសង្គ្រោះខ្លួនឯងពីបាប នោះក៏មិនបានកើតឡើយ ពីព្រោះអំពើបាបស៊ីបំផ្លាញអំពើល្អ។ លើសពីនេះទៀតពួកយើងបានបន្ថែមទោសនៃអំពើបាបតាមរយៈការប្រមាថព្រះអង្គ ហើយមិនដឹងគុណព្រះអង្គផងដែរ។ ដោយហេតុនេះបានជាយើងរាល់គ្នាត្រូវតែប្រឈមមុខនឹងការជំនុំជម្រះរបស់ព្រះជាម្ចាស់ជាមិនខាន។ ក៏ប៉ុន្តែ ព្រះស្រឡាញ់មនុស្សលោកខ្លាំងណាស់ អញ្ចឹងហើយបានជាព្រះជាម្ចាស់បានរៀបចំផ្លូវនៃសេចក្តីសង្គ្រោះតែមួយ ដោយបានចាត់ព្រះយេស៊ូវគ្រីស្ទឲ្យយាងមកផែនដីនេះ ដើម្បីសង្គ្រោះយើងឲ្យរួចផុតពីបាប និងលទ្ធផលនៃបាប។ ព្រះយេស៊ូវបានផ្ទុកអំពើបាប និងរងការជំនុំជម្រះ**ជំនួស**យើង ប្រយោជន៍ឲ្យយើងបានរាប់ជាសុចរិត មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ហើយក៏រំដោះយើងឲ្យរួចពីទោសនៃអំពើបាប និងស្ថាននរកផងដែរ។

សាសនាជួយយើងមិនបានមែន តែព្រះជាម្ចាស់បានរៀបចំផ្លូវមួយដើម្បីអាចសង្គ្រោះយើងបាន។ ជាធម្មតាយើងមិនចង់ពឹងផ្អែកលើព្រះទេ គឺយើងចូលចិត្តពឹងផ្អែកលើសមត្ថភាពខ្លួនឯងវិញ។ ប៉ុន្តែ បើសិនជាយើងមិនទទួលយកសេចក្តីសង្គ្រោះរបស់ព្រះ នោះយើងនឹងត្រូវទទួលការជំនុំជម្រះដ៏ធ្ងន់ធ្ងរនៅស្ថាននរក។













## តើអ្នកនឹងសម្រេចចិត្តទទួលយកសេចក្ដីសង្គ្រោះ ដែលប្រោសឲ្យរួចផុតពីអំពើបាបនេះដែរឬទេ?

ក្នុងនាមខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ខ្ញុំសុំអង្វរដល់អ្នករាល់គ្នាថា ចូរផ្សះផ្សាជានានឹងព្រះជាម្ចាស់វិញ តាមរយៈផ្លូវដែលទ្រង់បានរៀបចំឲ្យ ពីព្រោះគ្មានផ្លូវណាផ្សេងទៀតដែលនាំទៅរកសេចក្ដីសង្គ្រោះបានឡើយ។ ព្រះយេស៊ូវមានព្រះបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ»[17]។ ដូច្នេះ សូមទទួលយកព្រះយេស៊ូវជាព្រះជាម្ចាស់របស់អ្នក ហើយលន់តួបាបអ្នកដល់ទ្រង់ ទើបទ្រង់នឹងអត់ទោសបាបឲ្យអ្នក ដ្បិតព្រះគម្ពីរចែងថា «ប្រសិនបើយើងលន់តួបាបរបស់យើង នោះព្រះអង្គមានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ព្រះអង្គនឹងអត់ទោសបាបឲ្យយើង ហើយសម្អាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់»[18]។

បើអ្នកបានសម្រេចចិត្តជឿលើព្រះយេស៊ូវហើយ អ្នកបានក្លាយទៅជាកូនរបស់ព្រះជាម្ចាស់ ហើយអ្នកត្រូវរៀនថែមទៀតអំពីព្រះអង្គតាមរយៈការអានព្រះគម្ពីរ ហើយក៏ត្រូវចូលរួមថ្វាយបង្គំព្រះជាម្ចាស់នៅក្នុងក្រុមជំនុំព្រះយេស៊ូវគ្រីស្ទផងដែរ។៚

[17] ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ យ៉ូហាន ១៤:៦

[18] ដកស្រង់ពីព្រះគម្ពីរព្រះយេស៊ូវ កណ្ឌ ១ យ៉ូហាន ១:៩



ព្រះយេស៊ូវមានព្រះបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្តីពិត និងជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ។» (យ៉ូហាន ១៤:៦)